International Labour Organization | BetterWork | Cornell University ILR School

ILO brief

# គម្រោងការងារសមរម្យក្នុងសង្វាក់ផ្គត់ផ្គង់សំលៀកបំពាក់ក្នុងតំបន់អាស៊ី

ខែ ឧសភា ឆ្នាំ២០២១

## ឱកាសសម្រាប់អន្តរកាលប្រកបដោយយុត្តិធម៌ឆ្ពោះទៅរកចីរភាពបរិស្ថាន និងការស្តារឡើងវិញក្រោយវិបត្តិជំងឺកូវីដ ១៩ ក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរនៅតំបន់អាស៊ី

អន្តរកាលប្រកបដោយយុត្តិធម៌សម្រាប់ឧស្សាហកម្មកាត់ដេរក្នុងតំបន់អាស៊ី មានសារៈសំខាន់ណាស់ ព្រោះវិស័យនេះកំពុងខិតខំស្តារឡើងវិញពីផលប៉ះពាល់នៃជំងឺកូវីដ ១៩។ របាយការណ៍នេះនឹងពិនិត្យមើលផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ ១៩ លើវិស័យវាយនភណ្ឌ និងកាត់ដេរ ជាពិសេសផលប៉ះពាល់លើការងារ និងសហគ្រាស និងកំណត់បរិបទផលប៉ះពាល់ទាំងនេះក្នុងការអភិវឌ្ឍនៃវិស័យទាំងមូល (សង្គម សេដ្ឋកិច្ច និងបរិស្ថាន ទាំងវិជ្ជមាន និងអវិជ្ជមាន) ដើម្បីចោទសួរថាតើវិស័យនេះមានចីរភាពកម្រិតណា។

## វិស័យមួយដែលអំពាវនាវជាបន្ទាន់ឱ្យមានសកម្មភាពអន្តរកាលប្រកបដោយយុត្តិធម៌

មកទល់បច្ចុប្បន្ន យើងបានឆ្លងកាត់ផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ ១៩ អស់រយៈពេល ២ ឆ្នាំហើយ ប៉ុន្តែជំងឺនេះនៅតែបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើសុខភាព។ ប្រទេសជាច្រើននៅជុំវិញពិភពលោកកំពុងប្រឈមនឹងរលកទីពីរ និងរលកទីបីនៃជំងឺនេះ ដោយមានការអនុវត្តវិធានការផ្សេងៗ ដូចជា ការបិទខ្ទប់ ការបិទអាជីវកម្ម និងការបញ្ជាឱ្យស្នាក់នៅក្នុងផ្ទះ។ ផលប៉ះពាល់សុខភាពនៃជំងឺកូវីដ ១៩ ក្នុងតំបន់អាស៊ី កាន់តែមានភាពស្រួចស្រាវនៅឆ្នាំទីពីរនេះ ហើយផលប៉ះពាល់លើសេដ្ឋកិច្ច និងការងារនៅតែមានទំហំធំធេង។ របាយការណ៍នេះនឹងពិនិត្យមើលផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ ១៩ លើវិស័យវាយនភណ្ឌ និងកាត់ដេរ ជាពិសេសផលប៉ះពាល់លើការងារ និងសហគ្រាស និងកំណត់បរិបទផលប៉ះពាល់ទាំងនេះក្នុងការអភិវឌ្ឍនៃវិស័យទាំងមូល (សង្គម សេដ្ឋកិច្ច និងបរិស្ថាន ទាំងវិជ្ជមាន និងអវិជ្ជមាន) ដើម្បីចោទសួរថាតើវិស័យនេះមានចីរភាពកម្រិតណា។

ក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ វិស័យវាយនភណ្ឌ និងកាត់ដេរបានបង្កើតការងាររាប់លាន ភាគច្រើនសម្រាប់ស្ត្រី និងក្នុងសេដ្ឋកិច្ចផ្លូវការ។ វិស័យនេះបានផ្តល់ឱកាសសម្រាប់ឧស្សាហូបនីយកម្មឆាប់រហ័ស ជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងអន្តរជាតូបនីយកម្មតាមរយៈពាណិជ្ជកម្ម ដែលជួយឱ្យប្រទេសមានប្រាក់ចំណូលទាបក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យម និងស្រោចស្រង់ប្រជាជនរាប់លាននាក់ឱ្យរួចផុតពីភាពក្រីក្រធ្ងន់ធ្ងរ។ ទោះជាយ៉ាងណា វិស័យនេះបានបង្កផលប៉ះពាល់យ៉ាងខ្លាំងលើបរិស្ថាន ដូចជា ការប្រើប្រាស់ធនធានយ៉ាងច្រើនសម្រាប់ផលិតកម្ម (ថាមពល ដី ទឹក និងសារធាតុគីមី) និងការបង្កើតសំណល់ (ទឹកស្អុយ សំណល់រឹង សំណល់ពុល និងការបញ្ចេញជាតិពុលទៅក្នុងខ្យល់។ ផលប៉ះពាល់សង្គមក៏មានលក្ខណៈចម្រុះផងដែរ។ ទោះបីជាវិស័យនេះបានផ្តល់ការងារពិតមែន ប៉ុន្តែភាគច្រើនជាការងារដែលប្រើជំនាញតិច និងផ្តល់ប្រាក់ឈ្នួលទាប។ ការងារទាំងនេះច្រើនតែពាក់ព័ន្ធនឹងការងារថែមម៉ោង លក្ខខណ្ឌការងារមិនល្អ វិសមភាពយេនឌ័រ និងអំពើហិង្សា និងការបៀតបៀនផ្អែកលើយេនឌ័រ និងមានឱកាសតិចតួចក្នុងការបង្កើតគន្លងអាជីព និងការអភិវឌ្ឍជំនាញដែលអាចធានាផ្តល់ការងារដែលកាន់តែជាប់លាប់ និងផ្តល់ប្រាក់ឈ្នួលប្រសើរជាងមុន។ វិស័យនេះរួមបញ្ចូលមនុស្សយ៉ាងច្រើនក្នុង “working

poverty” ពោលគឺកម្មករដែលមិនអាចរកប្រាក់ចំណូលគ្រប់គ្រប់គ្រាន់សម្រាប់បំពេញចំណាយចាំបាច់ក្នុងគ្រួសារបាន (Anner 2020a, United Nations 2020)។

ភាពមិនទៀងទាត់នៃវិស័យនេះ លេចឡើងតាំងពីមុនការផ្ទុះឡើងនៃជំងឺកូវីដ ១៩ ប៉ុន្តែការបាត់បង់ការងារ និងការបិទសហគ្រាសដែលពាក់ព័ន្ធនឹងជំងឺកូវីដ ១៩ កំពុងបង្កផលជះអវិជ្ជមានលើការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងការងារក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ ដែលធ្លាប់តែមានភាពរីកចម្រើន។ ឧស្សាហកម្មមួយដែលធ្លាប់ទ្រទ្រង់ការងារ និងរបរចិញ្ចឹមជីវិតជុំវិញពិភពលោក កំពុងស្រុតចុះយ៉ាងខ្លាំង និងធ្វើឱ្យមានការរំលោភស្តង់ដារការងារ និងទាសភាពសម័យទំនើបក្នុងសង្វាក់ផ្គត់ផ្គង់សកល ហើយសកម្មភាពផលិតបង្កការបំពុលដី និងទឹកយ៉ាងធ្ងន់ធ្ងរនៅតាមបណ្តាប្រទេសដែលមានភាពក្រីក្រខ្លាំង និងដង់ស៊ីតេប្រជាជនខ្ពស់ (Niinimäki, Peters et al. 2020, Cole and Shirgholami 2021, ILO 2021a, ILO 2021b, ILO 2021c)។

ក្រោយពីទទួលរងផលប៉ះពាល់នៃជំងឺកូវីដ ១៩ ជាងមួយឆ្នាំកន្លងមក មានភស្តុតាងបង្ហាញយ៉ាងច្បាស់ថា កម្មករ និងសហគ្រាសដែលស្ថិតក្នុងបណ្តាញផលិតកម្មនៃសង្វាក់ផ្គត់ផ្គង់សកល ជាអ្នករ៉ាប់រងផលប៉ះពាល់ខ្លាំងជាងគេ ដោយសារការខាតបង់ និងការអាក់ខានដោយសារជំងឺរាតត្បាតនេះ និងវិលេចវិសមភាព និងអតុល្យភាពអំណាចយ៉ាងជ្រាលជ្រៅក្នុងសង្វាក់ផ្គត់ផ្គង់សកល។ ផលប៉ះពាល់ដែលបង្កឡើងដោយជំងឺកូវីដ ១៩ បានធ្វើឱ្យមានចម្ងល់ពាក់ព័ន្ធនឹងសក្តានុពលនៃការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យវាយនភណ្ឌ និងកាត់ដេរ និងលទ្ធភាពនៃការពន្លឿនអន្តរកាលប្រកបដោយយុត្តិធម៌ក្នុងវិស័យនេះ។

នៅចំពោះមុខគឺភាពចាំបាច់ក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើសង្គម និងបរិស្ថានដោយសារវិស័យនេះ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ឧបសគ្គផ្នែកធនធាន និងជម្នះបញ្ហាប្រឈមនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ តាមពិត កត្តាសំខាន់គឺការកំណត់យកចីរភាពសង្គម និងបរិស្ថានជាផ្នែកមួយនៃការស្តារឡើងវិញពីវិបត្តិជំងឺកូវីដ ១៩។ គ្មានពេលវេលាគ្រប់គ្រាន់ ឬលទ្ធភាពនៃការរង់ចាំឱ្យវិស័យនេះវិលត្រឡប់ទៅរកកម្រិតប្រហាក់ប្រហែលនឹងកម្រិត “ប្រក្រតីភាព” នៅអំឡុងមុនវិបត្តិនេះ មុននឹងចាត់វិធានការលើបញ្ហាទាំងនេះឡើយ។ របាយការណ៍នេះពិភាក្សាថាតើហេតុអ្វីចីរភាពបរិស្ថានគួរតែជាសមាសភាគស្នូលមួយនៃយុទ្ធសាស្ត្រ “ស្តារឡើងវិញឱ្យកាន់តែប្រសើរ” និងដោយរបៀបណា និងថាតើហេតុអ្វីយើងត្រូវកែលម្អរចនាសម្ព័ន្ធ និងយន្តការមានស្រាប់របស់យើងដើម្បីឱ្យការគ្រប់គ្រងសង្វាក់ផ្គត់ផ្គង់ជំរុញដល់ការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាព ឆ្ពោះទៅរកចីរភាពសង្គម និងបរិស្ថានទូទាំងវិស័យនេះ។ រចនាសម្ព័ន្ធមានស្រាប់មិនទាន់ផ្តល់លទ្ធផលរំពឹងទុកនោះទេ។ ការវិភាគនាពេលថ្មីៗនេះលើប្រសិទ្ធភាពនៃបទបញ្ញត្តិឯកជន ស្តីពីស្តង់ដារការងារក្នុងវិស័យនេះ បង្ហាញថា គ្មាន ឬមានភាពប្រសើរឡើងតិចតួចក្នុងរយៈពេល ៣ ទសវត្សរ៍កន្លងមក (Kuruvilla 2021)។ សូម្បីតែក្នុងអំឡុងពេលនៃវិបត្តិជំងឺកូវីដ ១៩ ក៏មានការកើនឡើងនៃភាពប្រកួតប្រជែងតម្លៃទាប (low price-point) ដែលបានជំរុញវិស័យនេះ និងដាក់សម្ពាធយ៉ាងខ្លាំងលើស្តង់ដារចីរភាពសង្គម និងបរិស្ថានផងដែរ។ ក្រុមហ៊ុនផលិតក្នុងប្រទេសផលិតសំលៀកបំពាក់ជាច្រើន (ដូចជា បង់ក្លាដេស កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ប៉ាគីស្ថាន និងវៀតណាម) ដែលចូលរួមក្នុងការអង្កេតនៅចុងឆ្នាំ ២០២០ លើកឡើងថា ជាមធ្យមតម្លៃដែលទទួលបានសម្រាប់មុខទំនិញដូចគ្នានៅឆ្នាំ ២០១៩ ថយចុះ ១២ ភាគរយធៀបនឹងឆ្នាំ ២០២០ ហើយរយៈពេលទូទាត់គឺយូរជាងមុន (Anner 2020a)។

ការទម្លាក់តម្លៃ មានន័យថា ក្រុមហ៊ុនផលិតងាយនឹងទទួលយកការបញ្ជាទិញក្រោមថ្លៃដើម ដែលជះឥទ្ធិពលដោយផ្ទាល់លើការបើកប្រាក់ឈ្នួលដល់និយោជិត និងការអនុលោមតាមបទបញ្ញត្តិ និងស្តង់ដារបរិស្ថាន។ នៅទូទាំងតំបន់អាស៊ី គេត្រូវផ្តោតសំខាន់លើសេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងសកម្មភាពផលិតកម្ម ដើម្បីធ្វើការវិភាគល្អិតល្អន់លើហានិភ័យ និងឱកាសក្នុងការកាត់បន្ថយកាបូន និងការបង្កើនចីរភាពសង្គម និងបរិស្ថានក្នុងវិស័យនេះ ក៏ដូចជាសហការគ្នាយ៉ាងសកម្មក្នុងការជះឥទ្ធិពលលើតួនាទីរបស់តំបន់អាស៊ីក្នុងវិស័យនេះ។ ដំណើរការអន្តរកាលប្រកបដោយយុត្តិធម៌ (ការសម្រេចបានអន្តរកាលចីរភាពតាមរបៀបដែលផ្តល់ “យុត្តិធម៌” ដល់កម្មករ និងសហគមន៍ពាក់ព័ន្ធ តាមរយៈការធានាថា គ្មាននរណាម្នាក់ត្រូវបានទុកចោល) គឺជាទស្សនាទានពាក់ព័ន្ធមួយក្នុងស្ថានភាពបច្ចុប្បន្ន។ គោលនយោបាយដែលលេចឡើង និងកិច្ចសន្ទនាសង្គមជុំវិញដំណើរការអន្តរកាលប្រកបដោយយុត្តិធម៌ នឹងផ្តល់មគ្គុទេសន៍ដ៏ល្អសម្រាប់ការរៀបចំសកម្មភាពស្តារឡើងវិញ និងការវិនិយោគដើម្បីជំរុញការស្តារវិស័យនេះប្រកបដោយចីរភាព។

**ព័ត៌មានទំនាក់ទំនង**

**ការិយាល័យ ILO ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច**
United Nations Building
Rajdamnern Nok Avenue
Bangkok 10200, Thailand

T: +66 2288 1234
F: +66 2280 1735
E: BANGKOK@ilo.org
W: www.ilo.org/asiapacific

©អង្គការអន្តរជាតិខាងការងារ ឆ្នាំ ២០២១